ចៀសវាងគំរបម្លប់ លប់បំបាត់ប្រភេទឈើដែលសំខាន់ៗ។

## ១.២ ការអនុវត្តន៍ការងារដាំដើមឈើ

***សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោម:***

ឧបសម្ព័ន្ធទី ១: ការជ្រើសរើសប្រភេទឈើ

ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្ដុះកូនឈើ

ឧបសម្ព័ន្ធទី ៤: ការងារនៅចំការដាំឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ទំព័របន្ថែមទី ១: ការគណនាបរិមាណគ្រាប់ពូជដែលត្រូវការ

# ២. ចំការឈើពហុប្រភេទ

## ២.១ យុត្តិកម្ម

ការដាំឈើជាទ្រង់ទ្រាយធំ មានលក្ខណៈសមស្របសំរាប់តំបន់ទាំងឡាយណាដែលគ្មានព្រៃឈើ ឬក៏នៅក្នុងតំបន់ដែលព្រៃឈើរេចរិលខ្លាំង មិនអាចអនុញ្ញាតឱ្យអនុវត្តការងារស្តារព្រៃឈើឡើងវិញកើត។

នៅក្នុងករណីខ្លះការបង្កើតចំការឈើដាំដោយប្រើប្រាស់ប្រភេទឈើជាច្រើនប្រភេទមានសារប្រយោជន៍ជាងចំការឈើឯកប្រភេទ។ ការដាំលាយគ្នានូវប្រភេទឈើជាច្រើនប្រភេទ មិនងាយរងនូវការបំផ្លាញពីជំងឺនិងសត្វល្អិតដោយហេតុថាកត្តាធាតុអាកាសប្រចាំតំបន់មានការផ្លាស់ប្តូរ (microclimate changes)។ លើសពីនេះទិន្នផល នៃចំការឈើក៏អាចមានការកើនឡើងប្រសិនបើប្រភេទឈើដែលដាំនោះមានលាយបញ្ចូលនូវអំបូរសិម្ពិកូលដែលមានលទ្ធភាពចាប់យកជីជាតិអាសូតពីបរិយាកាស ហើយម៉្យាងទៀតចំការឈើរបៀបនេះធានានូវសន្តិសុខហិរញ្ញវត្ថុ ដោយសារគេអាចប្រមូលផលឈើបានឆាប់ជាង (តាមរយៈការលាយបញ្ចូលនូវប្រភេទដែលឆាប់ផ្តល់ផល) និងជាបន្តបន្ទាប់។ ទោះបីជាវិធីសាស្ត្រនេះ មានលក្ខណៈស្មុគស្មាញក្នុងការបង្កើត និងគ្រប់គ្រងបន្តិចក្តី ប៉ុន្តែភស្តុតាងបានបង្ហាញថាការលាយចំរុះគ្នានូវប្រភេទឈើឱ្យបានសមស្រប នឹងផ្តល់អត្ថប្រយោជន៍ដ៏ធំធេង។

អត្ថប្រយោជន៍ផ្សេងៗទៀតចំពោះការអភិរក្សជីវចំរុះ ការការពារទីជំរាល អាចនឹងសំរេចបាននៅពេលដែលមានសកម្មភាពដាំដើមឈើនៅលើផ្ទៃដីធំធេង។ ការណ៍នេះមានន័យថា ជីវចំរុះក្នុងកំរិតមួយខ្ពស់អាចសំរេចបានតាមរយៈការលាយចំរុះគ្នានៃប្រភេទឈើជាច្រើននៅពេញតំបន់ទេសភាពធម្មជាតិទាំងមូល ឬក៏ការដាំឆ្លាស់គ្នានូវចំការ

ឈើឯកប្រភេទ។ ជីវចំរុះអាចនឹងត្រូវបានអភិរក្សបានយ៉ាងល្អប្រសើរ តាមរយៈការដាំឈើដោយប្រើប្រាស់ប្រភេទឈើជាច្រើនប្រភេទ។

## ២.២ ការអនុវត្តន៍

***ដាំឈើច្រើនប្រភេទក្នុងកំរិតដង់ស៊ីតេខ្ពស់:*** ដាំឈើជាច្រើនប្រភេទនៃប្រភេទឈើក្នុងស្រុកដែលដុះលូតលាស់លឿនក្នុងកំរិតដង់ស៊ីតេខ្ពស់ ដូច្នេះវាអាចគ្របស្មៅ និងទាក់ទាញពពួកសត្វព្រៃដែលជាភ្នាក់ងារពង្រាយគ្រាប់ពូជដែលជួយឱ្យមានការដុះដាលដោយធម្មជាតិនៃប្រភេទឈើក្នុងស្រុកជាបន្តទៀត។ វិធីសាស្ត្រនេះអាចអនុវត្តន៍សំរាប់ការស្តារនូវជីវចំរុះ។ យ៉ាងហោចណាស់ប្រភេទឈើចំនួន ២៥ ប្រភេទគួរត្រូវបានប្រើប្រាស់។ ការដាំឈើដោយគ្រាប់ផ្ទាល់ និង ការដាំបំពេញបន្ថែមដោយប្រើប្រាស់កូនឈើជាច្រើនប្រភេទ គួរតែអនុវត្តនៅកន្លែងណាដែលដីវាល ស្មៅអាចត្រូវបានកំចាត់ (ការពារ) និងមានលទ្ធភាពរកគ្រាប់ពូជនៃឈើជាច្រើនប្រភេទក្នុងបរិមាណដ៏ច្រើន។ លទ្ធផលដែលគួរឱ្យសង្ឃឹមទុកអាចនឹងសំរេចបានតាមរយៈការដាំឈើដោយប្រើប្រាស់ឈើច្រើនប្រភេទនិងក្នុងកំរិតដង់ស៊ីតេមួយខ្ពស់។ ក៏ប៉ុន្តែ ក្នុងការអនុវត្តន៍ជាក់ស្តែង ការងារនេះមានការលំបាកណាស់ ជាពិសេសចំពោះការអនុវត្តនៅលើផ្ទៃដីធំធេងដោយហេតុថា ម៉្យាងគេពិបាកក្នុងការស្វែងរកគ្រាប់ពូជនៃប្រភេទឈើជាច្រើនប្រភេទ និងម៉្យាងទៀតចំណាយលើការងារនេះក៏មាន ទំហំធំផងដែរ។

***ដាំឈើតែពីរ-បីប្រភេទក្នុងកំរិតដង់ស៊ីតេខ្ពស់:***

ដាំឈើនៃប្រភេទដែលបោះទីតាំងមុនពីរបីប្រភេទដើម្បីទាក់ទាញឱ្យពួកបក្សីនិងប្រចៀវនាំគ្រាប់ពូជពីដំណុះព្រៃដែលនៅសេសសល់ក្បែរនោះ។ជីវសាស្ត្រចំរុះអាចកើតមានឡើងវិញនៅពេលដែលដំណុះឈើដោយធម្មជាតិ បានចាប់ផ្តើម ប្រសិនបើមានដំណុះព្រៃល្អនៅសេសសល់ជិតនោះ ហើយប្រភេទឈើពីតំបន់នេះអាចចូលមកកាន់កាប់តំបន់ដែលទើបតែដាំឈើនោះបាន។

***សូមប្រើប្រាស់ទំព័របន្ថែម និង ឧបសម្ព័ន្ធនានាដូចខាងក្រោម:***

ឧបសម្ព័ន្ធទី ១: ការជ្រើសរើសប្រភេទឈើ

ឧបសម្ព័ន្ធទី ២: លទ្ធកម្មគ្រាប់ពូជ

ឧបសម្ព័ន្ធទី ៣: ការងារនៅថ្នាលបណ្តុះកូនឈើ

ឧបសម្ព័ន្ធទី ៤: ការងារនៅចំការដាំឈើ

ឧបសម្ព័ន្ធទី ៥: ការថែរក្សាចំការឈើដាំ

ឧបសម្ព័ន្ធទី ៦: គោលការណ៍ណែនាំសំរាប់ការធ្វើសេចក្តីសំរេចចិត្តក្នុងការស្តារដីព្រៃឡើងវិញ

ទំព័របន្ថែមទី ១: ការគណនាបរិមាណគ្រាប់ពូជដែលត្រូវការ